# ទស្សនវិជ្ជាអំពីស្ត្រី ៖ ការរំលូតកូន

*ដោយ មុិល វាសនា*

*មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*« ការរំលូតកូន » ជាបញ្ហាសង្គមមួយដែលត្រូវបានគេលើកយកមកជជែកវែកញែកយ៉ាងល្អិតល្អន់។ វាជាបញ្ហាដ៏សំខាន់ខាងផ្លូវច្បាប់និងនយោបាយនៅក្នុងបណ្តាប្រទេសឧស្សាហកម្ម។ ប្រទេសខ្លះមានការអនុញ្ញាតខាងផ្លូវច្បាប់ឱ្យមានការរំលូតកូន ប្រទេសខ្លះមានការហាមឃាត់ខាងផ្លូវច្បាប់ចំពោះការរំលូតកូន ប្រទេសខ្លះមាននយោបាយកម្រិតចំនួនកូននៅតាមគ្រួសារ ហើយប្រទេសខ្លះទៀតមាននយោបាយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋបង្កើតកូន។*

*ជាទូទៅ បញ្ហាដែលបានផ្តោតសំខាន់នៅក្នុងការជជែកវែកញែកនេះគឺលក្ខខណ្ឌសីលធម៌អំពីគភ៌ និងសិទ្ធិរបស់ស្ត្រីជាអ្នកមានផ្ទៃពោះ។ ការជជែកវែកញែកនេះក៏ទាក់ទងនឹងវិសាលភាពដែលគេគួរពិចារណាដែរ នោះគឺភាពក្រីក្រនិងចំនួនប្រជាជនច្រើន។*

*បញ្ហានៃការបន្តពូជជាប់ពាក់ព័ន្ធទៅនឹងមនុស្សទាំងពីរភេទ។ ទោះយ៉ាងណា ស្ត្រីតែងតែជាអ្នកវែកពន់នូវបន្ទុកនៃការបន្តពូជធ្ងន់ជាងបុរស។ បន្ថែមលើការឈឺចាប់ខាងផ្លូវកាយនិងភាពលំបាកនៃការពពោះនិងការឆ្លងទន្លេ ជាធម្មតា ស្ត្រីត្រូវបំពេញនូវតួនាទីជាច្រើនទៀត មានជាអាទិ៍ ការចិញ្ចឹមបីបាច់ថែរក្សា ការបញ្ចុកអាហារ ការស្លៀកពាក់ និង ការអប់រំកូន ជាដើម ។ ដូច្នេះ ផលវិបាកនៃការពុំបានពន្យាកំណើត ការរួមភេទមុនអាពាហ៍ពិពាហ៍ និងបញ្ហាផ្សេងៗទៀតស្រដៀងគ្នានេះ បានទម្លាក់បន្ទុកកាន់តែធ្ងន់ធ្ងរបន្ថែមទៀតទៅលើស្ត្រីច្រើនជាងបុរស។*

*សម្រាប់ក្មេងស្រី ការមានកូនដោយចៃដន្យនៅវ័យជំទង់អាចមានផលវិបាកពេញមួយជីវិត ហើយប្រឈមនឹងការមិនទទួលស្គាល់ក្នុងសង្គម ឬ ការបញ្ឈប់ការសិក្សា បន្ថែមទៅលើភាពគ្រោះថ្នាក់ផ្នែកសុខភាពនិងបន្ទុកនៃការពពោះ។ ហេតុនេះ ប្រធានបទស្តីពី ការរំលូតកូន គឺនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភជាខ្លាំងសម្រាប់ស្ត្រី ហើយបញ្ហានេះត្រូវបានគេលើកយកមកជជែកពិភាក្សាជាច្រើនដោយផ្តល់នូវទស្សនទានដោយឡែកៗគ្នា។ អត្ថបទនេះនឹងលើកឡើងពីទស្សនៈនានាទាក់ទងជុំវិញបញ្ហានៃការរំលូតកូនពិសេសផ្តោតទៅលើទិដ្ឋភាពនៃការជជែកដេញដោលគ្នាខាងផ្លូវច្បាប់និងខាងសីលធម៌ ជាដើម ។*

## ១- ទស្សនៈស្តីពីការរំលូតកូន

*ការរំលូតកូនជាការសម្លាប់គភ៌ឬស៊ុតបង្កកំណើតដោយចេតនាតាមរយៈការយកគភ៌ចេញពីស្បូនរបស់ម្តាយមុនពេលគភ៌នោះប្រសូត្រចេញពីផ្ទៃម្តាយ។*[1]

*ការរំលូតកូនជាបញ្ហាទូទៅដែលមនុស្សជាច្រើន រួមទាំងគិលានុប្បដ្ឋាកផង មានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយបញ្ហានេះនៅតែមានការពិភាក្សាវែកញែកជាបន្តបន្ទាប់អំពីក្រមសីលធម៌រក្សាការពារជីវិតនិងក្រមសីលធម៌ស្វ័យភាព ព្រមទាំងសិទ្ធិស្ត្រីក្នុងការគ្រប់គ្រងរាងកាយផ្ទាល់ខ្លួន។ ដំណោះស្រាយចំពោះបញ្ហានេះនៅតែចោទឡើងនិងមិនទាន់ប្រាកដប្រជានៅឡើយ។ គេមិនទាន់មានការឯកភាពគ្នាជាទូទៅនោះទេ ហើយច្បាប់នៅតាមបណ្តារដ្ឋនិងបណ្តាប្រទេសនានាបានលើកឡើងនូវកត្តាខុសៗគ្នា ដោយក្នុងនោះមានខ្លះលើកឡើងប្រកបដោយមនសិការដោយតម្រូវឱ្យគ្រូពេទ្យនិងគិលានុប្បដ្ឋាកម្នាក់ៗ ព្រមទាំងស្ថាបនផ្សេងៗ បដិសេធក្នុងការជួយរំលូតកូនប្រសិនបើការរំលូតកូននោះបំពានលើជំនឿសាសនា ឬ ក្រមសីលធម៌របស់គេ ឬខុសពីច្បាប់របស់គេដែលបានចែង។ ប៉ុន្តែ គិលានុប្បដ្ឋាកមិនមានសិទ្ធិឱ្យអ្នកជំងឺធ្វើតាមគំនិតរបស់ខ្លួននោះឡើយ។ តាមក្រមសីលធម៌នៃតំហែទាំ គឺគាំទ្រសិទ្ធិរបស់អ្នកជំងឺក្នុងការទទួលបានព័ត៌មាននិងការពិគ្រោះយោបល់អំពីការរំលូតកូន។*

*រហូតមកដល់បច្ចុប្បន្ន ការពន្យាកំណើតត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ។ ប៉ុន្តែមានទំនាស់កើតឡើងជាច្រើនក្នុងបណ្តាទស្សនវិទូទាក់ទងនឹងការពិភាក្សាស្តីពីការរំលូតកូននេះ។ ពួកគេមានការព្រួយបារម្ភជាចម្បងលើសំណួរផ្នែកផ្លូវចិត្តថា « តើការរំលូតកូនគឺជាទង្វើខុសឆ្គងដែរឬទេ? ហើយគាំទ្រនូវសំណួរទាក់ទងនឹងផ្លូវច្បាប់ថា តើការរំលូតកូនត្រូវបានហាមឃាត់ដោយច្បាប់ដែរឬទេ? » ។ ផ្អែកលើសំណួរផ្នែកផ្លូវចិត្តនេះ ទស្សនវិទូបានពិនិត្យលើជំហរដែលមានប្រជាប្រិយភាពបំផុតពីរ ហើយបានរកឃើញថា ជំហរទាំងពីរនេះមានបញ្ហាយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់មកពួកគេបន្តកែលម្អ និងការពារជំហរបន្ទាប់ទៀតរវាងទស្សនៈអ្នកសេរីនិយមនិងទស្សនៈអ្នកអភិរក្សនិយម។*

---

[1] *NICHOLAS BUNNIN AND JIYUAN YU* , The Blackwell Dictionary of Western Philosophy, First published 2004 by Blackwell Publishing Ltd

## *ទស្សនៈអ្នកអភិរក្សនិយម*

*ទស្សនៈអ្នកអភិរក្សនិយមយល់ថា ការរម្លូតកូនគឺជាទង្វើខុសឆ្គង ព្រោះវាទាក់ទងនឹងការសម្លាប់អាយុជីវិតមនុស្សដែលច្បាប់បានចែងថា «មនុស្សមានសិទ្ធិរស់រានមានជីវិត»។ អ្នកអភិរក្សនិយមបានទាញហេតុផលដូចខាងក្រោម៖*

*គភ៌ គឺជាមនុស្ស* (A fetus is a human being)

*មនុស្សទាំងអស់មានសិទ្ធិរស់រានមានជីវិត* (All human beings have a right to life)

*វាមិនត្រឹមត្រូវទេក្នុងការសម្លាប់អ្នកដែលគេមានសិទ្ធិរស់រានមានជីវិត* (It is wrong to kill anything with a right to life)។

*ដូច្នេះ ការរម្លូតកូនគឺជាកំហុសឆ្គង* (Therefore, abortion is wrong)

*ចំពោះទស្សនៈខាងលើនេះ មានទស្សនៈលើកឡើងជំទាស់លើពីរចំណុចជាចម្បង។ ទី១ គេយល់ស្របថា ប្រសិនបើការពពោះនៅតែបន្ត នោះគភ៌នឹងក្លាយជាមនុស្ស។ ត្រង់ចំណុចនេះ វាមិនទាន់ប្រាកដទេថា គភ៌អាចមានគុណសម្បត្តិគ្រប់គ្រាន់ជាមនុស្ស។ ទី២ ទោះបីគភ៌ជាមនុស្សក្តី ក៏ការសម្លាប់មនុស្សទាំងអស់មិនមែនសុទ្ធតែជាកំហុសឆ្គងនោះដែរ។ ឧទាហរណ៍ ករណីសម្លាប់មនុស្សដើម្បីការពារខ្លួន ការសម្លាប់មនុស្សនៅក្នុងសង្គ្រាម ការសម្លាប់មនុស្សដើម្បីសង្គ្រោះមនុស្សច្រើនគ្នា គឺសុទ្ធសឹងអាចត្រូវគេអនុញ្ញាតតាមក្រមសីលធម៌។*[2]

*ឆ្លើយតបទៅនឹងការជំទាស់នេះ អ្នកគិតមួយចំនួននៅក្នុងប្រពៃណីកាតូលិក បានធ្វើការកែលម្អនូវទស្សនៈអ្នកអភិរក្សនិយមដោយធ្វើការបង្ហាញពីការសម្លាប់ណាដែលជាកំហុសឆ្គងនិងការសម្លាប់ប្រភេទណាដែលគួរត្រូវបានអនុញ្ញាត។ មានទស្សនៈមួយបានលើកឡើងថា ខណៈដែលទង្វើដែលនាំទៅដល់ការស្លាប់ជីវិតគឺជាកំហុសឆ្គង នោះវាមិនមែនជាកំហុសឆ្គងទេក្នុងការរារាំងនូវសកម្មភាពណាមួយដែលជាសកម្មភាពការពារអាយុជីវិត។ នៅក្នុងស្ថានភាពរម្លូតកូនខណៈអាយុជីវិតស្ត្រីកំពុងទទួលរងការគំរាមកំហែង គឺគេអនុញ្ញាតឱ្យស្ត្រីស្លាប់ជាជាងការសម្លាប់គភ៌ដើម្បីសង្គ្រោះជីវិតរបស់នាង។*

*គំនិតចម្បងមួយទៀតនៅក្នុងប្រពៃណីកាតូលិក ការសម្លាប់ដោយផ្ទាល់គឺជាកំហុសឆ្គង រីឯការសម្លាប់ដោយប្រយោលគឺអាចមានលក្ខណៈសមស្រប។ ប្រសិនបើការសម្លាប់គភ៌ពាក់ព័ន្ធនឹងការវះកាត់យកស្បូនចេញ ឬ នីតិវិធីពេទ្យផ្សេងទៀតដែលធ្វើចំពោះស្ត្រីដែលមិនអាចពពោះបាន នោះគេគិតថាការសម្លាប់នោះជាការត្រឹមត្រូវ ព្រោះវាជាលទ្ធផលដោយប្រយោលនៃនីតិវិធី*

---

[2] Mary Vetterling-Bragging, Frederick A. Elliston & Jane English, *Feminism and philosophy*, 1981, P.378

ដែលគេធ្វើឡើងសម្រាប់ហេតុផលផ្សេងទៀត។ ទោះយ៉ាងណា ទស្សនៈនេះមិនមែនគាំទ្រឱ្យមនុស្សដាច់ខាតត្រូវធ្វើការរម្លូតកូននោះទេ។ គេអាចអនុញ្ញាតឱ្យសម្លាប់គភ៌ ដើម្បីសង្គ្រោះជីវិតស្រ្តីពីជំងឺមហារីកស្បូន ប៉ុន្តែគេហាមប្រាមការសម្លាប់គភ៌ដើម្បីសង្គ្រោះស្រ្តីពីជំងឺបេះដូង ដែលគភ៌ឬការសម្រាលបុត្រអាចបង្កគ្រោះថ្នាក់ដល់ស្រ្តី។

***ទស្សនៈអ្នកសេរីនិយម***

*អ្នកសេរីនិយមយល់ថា ការរម្លូតកូនមិនមែនជាកំហុសធ្ងន់ទេ ដោយគេសម្អាងថា គភ៌មិនទាន់មានលក្ខណៈឬគុណភាពជាមនុស្សនៅឡើយ។ អ្នកសេរីនិយមយល់ថា គភ៌គ្រាន់តែជាផ្នែកមួយនៃរាងកាយមនុស្សប៉ុណ្ណោះ។ អ្នកសេរីនិយមបានលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោម៖*

*គភ៌មិនទាន់មានលក្ខណៈជាមនុស្សនៅឡើយទេ តែគ្រាន់តែជាផ្នែកនៃរាងកាយរបស់ស្រ្តីប៉ុណ្ណោះ។* (A fetus is not a person but merely part of the women´s body)

*អ្នកមានសិទ្ធិធ្វើអ្វីដែលអ្នកចង់ធ្វើនៅក្នុងរាងកាយនិងលើរាងកាយផ្ទាល់របស់អ្នក* (You have a right to do whatever you want in and to your own body)

*ដូចនេះអ្នកមានសិទ្ធិធ្វើការរម្លូតកូន។*[3] (Therefore, you have a right to have an abortion)

*ទោះបីយ៉ាងណា ទស្សនៈនេះក៏មានបញ្ហាមួយចំនួនផងដែរ។ បញ្ហាទី១ វាពុំត្រឹមត្រូវទេដែលថា អ្នកអាចធ្វើអ្វីដែលអ្នកចង់ធ្វើចំពោះរាងកាយផ្ទាល់របស់អ្នក។ អ្នកមិនអាចសម្លាប់ខ្លួនឯងដោយការបំផ្ទុះគ្រាប់នៅនឹងខ្លួនក្នុងចំណោមហ្វូងមនុស្សម្នាដ៏ច្រើននៅក្បែរខ្លួនអ្នកនោះទេ ព្រោះទង្វើបែបនេះធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ ទោះបីវាគឺជារាងកាយរបស់អ្នកក៏ដោយ។ បញ្ហាទី២ ទោះបីយើងនិយាយថា គភ៌មិនទាន់មានលក្ខណៈជាមនុស្សក្តី ក៏មិនមែនមានន័យថា អ្នកអាចធ្វើអ្វីស្រេចចិត្តនោះដែរ។ អ្នកមិនអាចសម្លាប់ហ្វូងបក្សីដោយគ្មានមូលហេតុនោះទេ ទោះបីពួកវាមិនមែនជាមនុស្សក្តី។ លក្ខណៈស្រដៀងគ្នានេះដែរគឺថា ទោះបីជាគភ៌ប្រៀបដូចជាសត្វនិងមិនមានលក្ខណៈជាមនុស្សក៏ដោយ ក៏វាអាចមានសិទ្ធិខ្លះៗដែរ។ វាជាកំហុសមួយដ៏ធ្ងន់ធ្ងរដែលយើងធ្វើទារុណកម្មសត្វឆ្កែដើម្បីគ្រាន់តែជាល្បែងកម្សាន្ត ឬ យកឆ្កែមកធ្វើពិសោធន៍ ធ្វើការស្រាវជ្រាវសម្រាប់ផលប្រយោជន៍របស់មនុស្ស។ មនុស្សភាគច្រើនគិតថា វាជាការត្រឹមត្រូវក្នុងការសម្លាប់បក្សីធ្វើជាអាហារឬការពារផលដំណាំរបស់យើង។ ជាការពិត សិទ្ធិមនុស្សគឺខុសពីសិទ្ធិរបស់សត្វ*

---

[3] Mary Vetterling-Bragging, Frederick A. Elliston & Jane English, *Feminism and philosophy*, 1981, P.379

*ហើយវាជាកំហុសក្នុងការធ្វើពិសោធរបស់មនុស្ស ទោះបីជាវាផ្តល់ផលប្រយោជន៍យ៉ាងច្រើនពីលទ្ធផលនៃការលះបង់របស់សត្វទាំងនោះក៏ដោយ។*

*មានសំណួរចោទសួរថា តើយើងគួរធ្វើដូចម្តេចចំពោះភាវៈមិនមែនជាមនុស្ស? យើងមិនចង់និយាយថា ការធ្វើទារុណកម្មទៅលើសត្វក្តែគឺមិនចោទជាបញ្ហានោះទេ។ ប្រសិនបើយើងធ្វើទារុណកម្ម ឬសម្លាប់សត្វក្តែជាលក្ខណៈបុគ្គល ឬ ក៏ករណីដែលយើងរស់នៅលើវាលខ្សាច់ដាច់ស្រយាលឬស្ថិតក្នុងស្ថានភាពមួយលំបាកអាចនឹងស្លាប់ នោះការប្រព្រឹត្តទាំងនោះនឹងមិនប៉ះពាល់ដល់មនុស្សនោះទេ ព្រោះយើងធ្វើដើម្បីការពារជីវិតរបស់យើង។*

*នៅឆ្នាំ១៩៧១ លោក* Judith Jarvis Thomson (*ទស្សនវិទូខាងសីលធម៌*) *បានលើកឡើងនៅក្នុងស្នាដៃស្តីពី* « A Defense of Abortion » *ថា ការរំលូតកូនគួរត្រូវបានអនុញ្ញាតខាងសីលធម៌ ទោះបីគភ៌បានក្លាយជាមនុស្សហើយក្តី ពីព្រោះសិទ្ធិរស់រានមានជីវិតមិនរាប់បញ្ចូលនៅក្នុងសិទ្ធិមិនត្រូវបានសម្លាប់នោះទេ ប៉ុន្តែរាប់បញ្ចូលនៅក្នុងសិទ្ធិដែលមិនត្រូវសម្លាប់ដោយអយុត្តិធម៌។ ប្រសិនបើស្ត្រីបញ្ចប់ជីវិតគភ៌របស់នាងនៅក្នុងវិធីដែលត្រូវបានគេពិចារណាថាត្រឹមត្រូវ នោះមិនមានសិទ្ធិរស់រានមានជីវិតរបស់នរណាម្នាក់ត្រូវបានបំពាននោះទេ។*[4]

*បច្ចុប្បន្ននេះមានការលើកឡើងថា នៅដំណាក់កាលដំបូងនៃការមានគភ៌ ការរំលូតកូនឬការសម្លាប់គភ៌មិនមែនជាបញ្ហានោះទេ ហើយគេគួរតែអនុញ្ញាត ជាពិសេសចំពោះគភ៌ដែលមិនមានលក្ខណៈប្រក្រតី ទោះបីវាត្រូវវិវត្តទៅមុខទៀតក៏ដោយ។ ពីមុន វិទ្យាសាស្ត្រពុំទាន់មានការរីកចម្រើន មនុស្សនៅពុំទាន់ស្វែងយល់បានពីគភ៌ ថាតើវាមានលក្ខណៈឬគុណភាពជាមនុស្សឬអត់នោះឬនៅដំណាក់កាលណាដែលគេនឹងក្លាយជារូបរាងពេញជាមនុស្ស នោះពួកគេពុំដឹងថា ការរំលូតកូនជាកំហុសធ្ងន់នោះទេ។ ហេតុនេះ ពួកគេគិតថា ច្បាប់មិនគួរហាមប្រាមគេពីការរំលូតកូននោះទេ។ ពួកគេគិតថា គេមានសេរីភាពក្នុងការធ្វើបែបនេះ ហើយការហាមឃាត់ពួកគេគឺជាការបំបិទសិទ្ធិសេរីភាពរបស់គេ និងជ្រៀតជ្រែកដល់សុខទុក្ខផ្ទាល់ខ្លួនរបស់គេ។ ពេលនេះមនុស្សគិតថា ការរំលូតកូនជាការខុសធ្ងន់ ហើយប្រសិនបើវាជាអំពើបាបធ្ងន់ធ្ងរ និង ខ្លាំងជាងការរារាំងសិទ្ធិស្ត្រីក្នុងការគ្រប់គ្រងលើខ្លួនរបស់គេផ្ទាល់ នោះវាជាការត្រឹមត្រូវដែលច្បាប់ធ្វើការហាមប្រាមមិនឱ្យស្ត្រីរំលូតកូនស្រេចតែចិត្ត។*

*យើងឃើញថា ការជជែកគ្នាជាលក្ខណៈប្រពៃណីទៅលើការប្រឆាំងទៅនឹងការរំលូតកូនឬយកកូនចេញ គឺត្រូវបានផ្តោតទៅលើលក្ខណៈមួយចំនួនដែលថា គភ៌មានលក្ខណៈប្រហាក់ប្រហែលនឹងទារកទៅហើយ។ ពួកគេបានបញ្ជាក់នូវការវិវឌ្ឍរបស់វាដោយមិនផ្តោតទៅលើភាព*

[4] Ned Resnikoff , *Philosophy and the moral issue of abortion,* 01/23/13 04:08PM – UPDATE 09/13/13 08:47AM

ដែលគ្មានលក្ខណៈស្រដៀងគ្នាទៅនឹងមនុស្សពេញវ័យនោះទេ។ ពួកគេបានព្យាយាមបង្ហាញនូវសមានចិត្តដែលជាផ្នែកមួយធ្វើឱ្យយើងមានអារម្មណ៍ចំពោះមនុស្សផ្សេងទៀត។ លក្ខណៈទាំងអស់នេះគឺដើម្បីធ្វើការបញ្ចុះបញ្ចូលយើងថា គភ៌ត្រូវតែសមលក្ខណៈជាមនុស្ស។ កំណត់សម្គាល់មួយទៀតទៅលើគភ៌ដែលជិតចាប់កំណើត(ចាស់ខែ) គឺវាត្រូវការបំពេញនិងបំប៉ន និងកត្តាផ្សេងៗទៀតជាច្រើនជាជាងគភ៌ដែលទើបនឹងមានអាយុខ្ចីនិងទើបតែវិវឌ្ឍ។ ហេតុផលដែលថា ស្ត្រីត្រូវគេចាប់រំលោភហើយក្នុងករណីមានកូន គួរស្វែងរកការរម្លូតកូនចោលគឺមិនសមរម្យនោះទេ។

ទស្សនៈខាងអភិរក្សនិយមខុសពីទស្សនៈខាងសេរីនិយម។ អ្នកខាងអភិរក្សនិយមយល់ថា ការរម្លូតកូនគឺជាកំហុសធ្ងន់ ព្រោះវាជាការសម្លាប់មនុស្សប្រៀបដូចជាឃាតករ។ ប៉ុន្តែគេអះអាងថា មិនមែនការសម្លាប់ទាំងអស់សុទ្ធតែជាឃាតករនោះទេ ដូចជា ការសម្លាប់ដើម្បីការពារខ្លួនជាដើម គឺគ្មានកំហុសធ្ងន់ទេ។ ផ្ទុយទៅវិញអ្នកខាងសេរីនិយមហាក់ដូចជាមានកំហុសធ្ងន់ក្នុងអំណះអំណាងរបស់គេ។ អ្នកសេរីនិយមយល់ថា គភ៌មិនទាន់មានលក្ខណៈជាមនុស្សនៅឡើយទេរហូតដល់វាកើត ហេតុនេះស្ត្រីមានសិទ្ធិធ្វើអ្វីៗបានទាក់ទងនឹងរាងកាយរបស់គេ។ ប៉ុន្តែ ពួកគេបានលើកឡើងនូវហេតុផលពីរ។ ហេតុផលទី១ ស្ត្រីមិនអាចធ្វើអ្វីដែលខ្លួនចង់បានទេទាក់ទងនឹងរាងកាយរបស់គេ ប្រសិនបើវាប៉ះពាល់ដល់អ្នកដទៃ។ ហេតុផលទី២ ទោះបីគភ៌មិនទាន់ក្លាយជាមនុស្ស ប៉ុន្តែយើងគ្មានសិទ្ធិធ្វើអ្វីៗស្រេចតែចិត្តដែលយើងចង់នោះដែរ។ អ្នកសេរីនិយមអះអាងដោយផ្តល់ឧទាហរណ៍ថា សត្វមិនមែនជាមនុស្សទេ ប៉ុន្តែការសម្លាប់ឬធ្វើទារុណកម្មណាមួយលើសត្វ គឺជាកំហុសធ្ងន់។ និយាយរួម ទស្សនៈទាំងពីរមានហេតុផលត្រឹមត្រូវរៀងៗខ្លួន។ យើងឃើញថា ទោះបីគភ៌ជាមនុស្សក្តី ក៏ការរម្លូតកូនអាចត្រឹមត្រូវក្នុងករណីមួយចំនួនដែរ ហើយទោះបីគភ៌មិនទាន់មានលក្ខណៈជាមនុស្សក្តី ក៏ករណីមួយចំនួនការសម្លាប់វាជាកំហុសធ្ងន់ដែរ។

## ២- ការរម្លូតកូននិងការការពារខ្លួន

ច្បាប់នៅបណ្តាប្រទេសអឺរ៉ុប ចាប់ពីសតវត្សទី ១៧ មក ការរម្លូតកូនគឺប្រៀបបានទៅនឹងការសម្លាប់ជីវិតមនុស្ស។ យើងមិនអាចគិតពីពេលវេលាជាក់លាក់ណាមួយនៅពេលដែលមនុស្សលេចចេញជារូបរាងនោះទេ។ ទោះយ៉ាងណា នៅមានការពិភាក្សាគ្នាវាងបញ្ហាដែលលើកឡើងថា គភ៌ក្នុងផ្ទៃគឺជាមនុស្សគ្មានកំហុស ហើយថាការសម្លាប់តែងតែជាកំហុស។ ប៉ុន្តែ ពេលខ្លះការសម្លាប់មនុស្សដែលគ្មានកំហុស គឺត្រូវបានគេអនុញ្ញាតនៅក្នុងករណីការពារខ្លួន។

ឧបមាថា អ្នកវិទ្យាសាស្ត្រឡប់សតិម្នាក់បានសណ្តំមនុស្សម្នាក់គ្មានកំហុស ហើយបានចាក់មនុស្សនោះនឹងកាំបិត។ ក្នុងករណីនេះ យើងមានសិទ្ធិសម្លាប់អ្នកវិទ្យាសាស្ត្រ ដែលព្យាយាម

សម្ងាប់ជីវិតយើងបានដោយយកហេតុផលថា ការពារខ្លួន ប្រសិនបើនេះជាវិធីតែមួយគត់ក្នុងការសង្គ្រោះជីវិតយើងឱ្យផុតពីរបួសធ្ងន់ធ្ងរដែលអាចប៉ះពាល់ដល់អាយុជីវិត។ វាមិនមានបញ្ហាអ្វីទេ ទោះបីអ្នកព្យាយាមធ្វើបាបយើងជាមនុស្សគ្មានកំហុសក៏ដោយ គឺយើងធ្វើបែបនេះដើម្បីការពារខ្លួនយើង។

ក្នុងទិដ្ឋភាពផ្លូវច្បាប់និងប្រពៃណីរបស់យើង គឺមិនចង់ឱ្យយើងបង្ករបួសស្នាមទេ សូម្បីតែបន្តិចបន្តួចក៏ដោយ។ មានន័យថា បើយើងអាចជៀសវាងពីទង្វើនេះបានគឺយើងគួរតែជៀសវាងឱ្យផុតឱ្យអស់ពីលទ្ធភាពរបស់យើង។ យើងត្រូវកាត់បន្ថយឱ្យបានទាបបំផុតនូវគ្រោះថ្នាក់ ទោះយើងដឹងថា គេព្យាយាមចង់សម្លាប់យើងក៏ដោយ ហើយយើងអាចរកមធ្យោបាយផ្សេងៗទៀតដោយគេចចេញពីជម្លោះជាការប្រសើរ។ ការការពារខ្លួន គឺធ្វើឡើងក្នុងគោលបំណងបញ្ចៀសគ្រោះថ្នាក់។ ក្នុងករណីខ្លះ ការមានផ្ទៃពោះបង្ហាញពីស្ថានភាពស្របគ្នា។ ទោះបីជាគភ៌ក្នុងផ្ទៃជាមនុស្សគ្មានកំហុស តែបើវាមានផលប៉ះពាល់ដល់ជីវិតម្តាយនិងសុខភាពម្តាយ នោះការការពារខ្លួនគឺអាចធ្វើទៅបានដោយវិធីយកកូនចេញដើម្បីសង្គ្រោះម្តាយ។ ប៉ុន្តែបើវាបង្កគ្រោះថ្នាក់តិចតួចគភ៌គួរត្រូវបានថែរក្សានិងគាំពារ។

ស្ត្រីមានសិទ្ធិរួចផុតពីការមានគភ៌ មិនមែនជាសិទ្ធិទាមទារការសម្លាប់នោះទេ។ របៀបនៃការការពារខ្លួន គឺមានប្រយោជន៍បំផុតនៅពេលយើងគិតពីទស្សនៈរបស់ស្ត្រីមានផ្ទៃពោះ។ ក្នុងនាមជាវេជ្ជបណ្ឌិតគឺត្រូវគិតថា តើខ្លួនមានសិទ្ធិធ្វើការជ្រើសរើសរវាងជីវិតម្តាយនិងគភ៌ឬ? យើងគ្មានសិទ្ធិនិងហេតុផលសម្រាប់អ្នកណាម្នាក់ ដើម្បីហេតុផលឬការការពារអ្នកណាមួយទៀតនោះទេ។ របៀបនៃការការពារខ្លួនបញ្ជាក់ថា ស្ត្រីអាចមានបំណងរម្លូតកូន តែវេជ្ជបណ្ឌិតមិនគួរជួយទេ។

តួនាទីរបស់ភាគីទីបីគឺមានលក្ខណៈស្មុគស្មាញបន្តិច។ យើងចង់ជួយជនរងគ្រោះ ប៉ុន្តែបើភាគីទាំងពីរគ្មានទោស គឺយើងត្រូវធ្វើការពិចារណា។ ឧទាហរណ៍ថា អ្នកជាប្រជារាស្ត្រទន់ខ្សោយដែលចង់ជៀសវាងពីគ្រោះថ្នាក់ណាមួយ ដូច្នេះអ្នកត្រូវជួលអង្គរក្សដើម្បីការពារខ្លួន។ ប្រសិនបើអ្នកត្រូវគេធ្វើបាប យើងជឿជាក់ថា អង្គរក្សរបស់អ្នកមានសិទ្ធិក្នុងការសម្លាប់អ្នកធ្វើបាបនោះដើម្បីសង្គ្រោះអ្នកឱ្យរួចផុតពីការវាយប្រហារប្រកបដោយគ្រោះថ្នាក់នោះ។ ដូចនេះ សិទ្ធិរបស់អ្នកក្នុងការការពារខ្លួនត្រូវបានផ្ទេរទៅឱ្យភ្នាក់ងាររបស់អ្នក។

វេជ្ជបណ្ឌិតក៏ដូចគ្នា គឺត្រូវបានចាត់ទុកជាភ្នាក់ងាររបស់ស្ត្រីមានផ្ទៃពោះក្នុងការអនុវត្តការការពារ នៅពេលស្ត្រីមិនអាចសម្រេចការងារដោយខ្លួនឯងបានតាមលក្ខណៈរូបសាស្ត្រ។ ជាក់ព្

សំណាង ដោយសារបច្ចេកវិទ្យារីកចម្រើនខ្ពស់ មិនសូវមានបញ្ហាចោទចំពោះស្ត្រីមានផ្ទៃពោះលើការគំរាមកំហែងខាងសុខភាពរាងកាយស្ត្រីឡើយ។

តាំងពីពេលមានគភ៌រហូតគ្រប់អាយុនៃគភ៌ ស្ត្រីមិនតម្រូវឱ្យធ្វើការធ្ងន់ឬធ្វើពលិកម្មធ្ងន់ធ្ងរឡើយ គឺដើម្បីសុខភាពម្ដាយនិងគភ៌។ មានការអប់រំថា ក្នុងករណីស្ត្រីមានផ្ទៃពោះទទួលរងការរំលោភផ្លូវភេទ ស្ត្រីត្រូវបណ្ដោយខ្លួនទៅតាមចំណង់របស់គេដោយសម្រួល។ នេះមិនមែនមានន័យថា ជននោះមានសិទ្ធិធ្វើដូចនេះទេ ប៉ុន្តែការធ្វើព្រងើយកន្តើយរបស់ស្ត្រី គឺដើម្បីរក្សាកូននៅក្នុងផ្ទៃមិនឱ្យរលូត។ ទោះការមានគភ៌ជាបន្ទុកមួយដ៏លំបាក ប៉ុន្តែគួរមានច្បាប់ហាមឃាត់ក្នុងកម្រិតណាមួយទាក់ទងនឹងការរម្លូតកូននេះ។

មានវិធីជាច្រើនដើម្បីការពារខ្លួនស្ត្រីពីការមានផ្ទៃពោះ ដូចជា ត្រណាមការរួមភេទ ការប្រើវិធីបែបធម្មជាតិ ឬ ប្រើថ្នាំពន្យាកំណើត។ វិធីទាំងអស់នេះមិនចោទជាបញ្ហាអ្វីនោះទេ។ ប៉ុន្តែការរម្លូតកូនគឺជាទង្វើខុសឆ្គងទោះថាមានបរាជ័យក្នុងការប្រើវិធីពន្យាកំណើតក៏ដោយ។ យើងអាចសម្លាប់ជនខិលខូចនៅពេលដែលបុគ្គលនោះពិតជាចង់សម្លាប់យើង ប៉ុន្តែបើបុគ្គលណាម្នាក់មានបំណងត្រឹមតែធ្វើឱ្យអ្នកត្រឹមតែមានរបួសស្នាម នោះអ្នកមិនត្រូវសម្លាប់បុគ្គលនោះឡើយ។ នេះប្រៀបដូចជាស្ថានភាពនៃការរម្លូតកូនត្រូវបានអនុញ្ញាត បើមានការសង្គ្រោះជីវិតស្ត្រី។

សរុបមក ការសម្លាប់គភ៌ដើម្បីសង្គ្រោះជីវិតម្ដាយ និងការពារខ្លួនម្ដាយ គឺជាហេតុផលមួយសមស្រប ប៉ុន្តែការសម្លាប់ក្នុងហេតុផលផ្សេងទៀតគឺមិនសមស្របនោះទេ។ វានៅមានករណីជាច្រើនទៀតទាក់ទងនឹងការសម្លាប់គភ៌ ដែលត្រូវធ្វើយុត្តិកម្មក្នុងពេលបច្ចុប្បន្ន។ ទស្សនៈមួយចំនួនយល់ថា ស្ត្រីមានគភ៌ដោយសារត្រូវគេរំលោភ ស្ត្រីវ័យក្មេងមានគភ៌ដោយសារខ្លួនភ្លើតភ្លើនឬល្ងង់ខ្លៅ ស្ត្រីមានគភ៌ដែលប្ដីត្រូវស្លាប់ដោយយថាហេតុអ្វីមួយ ឬ ការប្រែប្រួលនៃស្ថានភាពគ្រួសារដែលធ្វើឱ្យស្ត្រីមានការលំបាក គឺស្ត្រីទាំងអស់នេះមានសិទ្ធិក្នុងការសម្រេចចិត្តថា ត្រូវទុកគភ៌នេះបន្តទៀត ឬ ត្រូវរម្លូតចោល។ យើងឃើញថា បញ្ហានេះទាក់ទងនឹងការសម្រេចចិត្តប្រកបដោយទំនួលខុសត្រូវ បើយើងចង់រក្សាទុកគភ៌បន្តទៀត នោះយើងត្រូវមានទំនួលខុសត្រូវក្នុងការថែរក្សានិងចិញ្ចឹមបីបាច់អប់រំបន្ទាប់ពីយើងបានផ្ដល់កំណើតរួច។ ទាក់ទងបញ្ហានេះ មានសំណួរចោទសួរថា តើស្ត្រីទាំងនោះអាចបំពេញកាតព្វកិច្ចនេះបានដែរឬទេ?

## ៣- ការរំលូតកូននិងគុណភាពនៃជីវិត

សម័យបច្ចុប្បន្ន មានទស្សនៈតិចតួចណាស់ដែលបានបង្ហាញនូវការព្រួយបារម្ភចំពោះស្ត្រី ដែលត្រូវសម្រេចចិត្តថា ត្រូវរក្សាគភ៌ឬត្រូវរំលូតកូនចេញ(យកកូនចេញ)។ ទស្សនវិទូទាំងឡាយពុំបានធ្វើការសាកល្បង កត់សម្គាល់ វិភាគ អំពីប្រភេទនៃហេតុផលដែលគាំទ្រដល់ការសម្រេចចិត្តនោះទេ។ ផ្ទុយទៅវិញ ពួកគេបែរជាផ្តោតទៅលើចំណោទសួរ ថាតើគភ៌ជាមនុស្សឬទេ? ហើយគេមានសិទ្ធិរស់រានមានជីវិតឬទេ? ដោយសារគ្មានកិច្ចពិភាក្សាស៊ីជម្រៅអំពីការរំលូតកូន នោះក៏មិនទាន់មានដំណោះស្រាយសមស្របមួយខាងមគ្គុទេសន៍ទស្សនវិជ្ជាសីលធម៌ដែរ។ អ្នកជំទាស់នឹងការរំលូតកូនបានព្យាយាមបង្ហាញថា ទោះបីស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយ ក៏មិនគួរមានច្បាប់អនុញ្ញាតឱ្យមានការរំលូតកូននោះដែរ។ ប៉ុន្តែចំពោះអ្នកគាំទ្រឱ្យមានការរំលូតកូនគឺផ្តល់អាទិភាពទៅលើស្ត្រីជាធំក្នុងការសម្រេចចិត្តថា តើគួររក្សាគភ៌ឬអត់ ទាក់ទងនឹងស្ថានភាពផ្ទាល់របស់ស្ត្រី ជាពិសេសការរំលូតកូនដើម្បីការពារខ្លួនស្ត្រីផ្ទាល់ឬក៏គភ៌មានលក្ខណៈមិនប្រក្រតី។

ការបង្ហាញហេតុផលគ្រប់គ្រាន់ខាងសេដ្ឋកិច្ច សង្គម និងខាងចិត្តវិទ្យា ហើយសម្រេចចិត្តធ្វើការរំលូតកូនចេញ គឺពុំត្រឹមត្រូវទាំងស្រុងនៅឡើយទេ។ ស្ត្រីជាច្រើនធ្វើការរំលូតកូនដោយផ្អែកលើហេតុផលទាំងនេះ ក្នុងនោះរួមមានការលើកឡើងនូវហេតុផលថា ខ្លួនមានកូនច្រើននិងគ្មានលទ្ធភាពចិញ្ចឹមបីបាច់ថែរក្សាឬអប់រំគេឱ្យបានល្អនោះទេ ខណៈមានមនុស្សមួយចំនួនលើកឡើងអំពីហេតុផលខាងហិរិញ្ញវត្ថុ និងអ្នកខ្លះទៀតលើកឡើងថា ដោយសារពួកគេមិនបានឆ្លងកាត់អាពាហ៍ពិពាហ៍។ ក្រៅពីនេះ មានហេតុផលផ្សេងទៀតលើកឡើងអំពីការស្លាប់របស់ស្វាមី ដោយសារគេរំលោភ មកពីភាពល្ងង់ខ្លៅ ការផឹកស្រាស្រវឹង និងការជ្រុលជ្រួសនឹងគ្នាដោយមិនបានពិចារណា ជាដើម។ មានការអះអាងថា វាហាក់ដូចជាធ្វើបាបស្ត្រីពេកចំពោះការឱ្យស្ត្រីធ្វើការលះបង់ខ្ពស់ ដោយសុខចិត្តទ្រាំនូវការលំបាកពពោះ សម្រាលកូន និង ចិញ្ចឹមថែរក្សាកូន ទាំងគ្មានគោលដៅបែបនេះ។ គេគួរមើលឃើញថា ដោយសារការលំបាកទាំងឡាយដែលស្ត្រីត្រូវប្រឈមមុខទាំងនេះហើយទើបជំរុញឱ្យស្ត្រីត្រូវសម្រេចចិត្តថានឹងរំលូតកូនចេញ។ ហេតុផលនេះ គឺទាក់ទងនឹងគុណភាពនៃជីវិត។

ការពិចារណាអំពីគុណភាពនៃជីវិត ត្រូវបានគេទទួលស្គាល់ក្នុងការធ្វើការសម្រេចចិត្តអំពីសមាសភាពគ្រួសារ និង ការប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងកំណើត។ ស្ត្រីធ្វើការពិចារណាថា ការរក្សាគភ៌ គឺត្រូវគិតអំពីទំនួលខុសត្រូវផ្ទាល់របស់គេចំពោះទារក ក៏ដូចជាការចិញ្ចឹមបីបាច់ថែរក្សាជីវិតទារកនេះជាបន្តបន្ទាប់ដែរ។ យើងឃើញថា ទំនៀមទម្លាប់អាចរាលដាលយ៉ាងលើសលប់ទៅ

លើផែនការគ្រួសារបុគ្គលផ្ទាល់តាំងពីដើមរៀងមក។ គោលការណ៍សំខាន់នៃផែនការគ្រួសារគឺដើម្បីពង្រឹងគុណភាពជីវិតបុគ្គលម្នាក់ៗ ហើយក៏សម្រាប់សង្គមទាំងមូលផងដែរ។ ការយល់ដឹងអំពីជីវវិទ្យានៃការបង្កើតកូនចៅរបស់មនុស្ស និងការរីកចម្រើនខាងបច្ចេកវិទ្យានៃការមិនឱ្យមានកូន បានផ្តល់នូវអត្ថប្រយោជន៍ដល់ប្រជាជន ដើម្បីបង្កើនកម្រិតនៃការត្រួតពិនិត្យរបស់ពួកគេ។ លក្ខខណ្ឌមួយដែលល្អសម្រាប់ប្រជាជនទូទៅគឺចំនួនសមាជិកក្នុងក្រុមគ្រួសារដែលមានលក្ខណៈសមស្របទៅតាមលទ្ធភាពនៃការរកប្រាក់ចំណូល ឬ ការចេះចែករំលែកទ្រព្យសម្បត្តិនិងការជួរឱ្យគ្នា។ បច្ចុប្បន្ន ភាពកម្រនៃធនធាន ការកើនឡើងនៃចំនួនប្រជាជន ការបែងចែកទ្រព្យសម្បត្តិមិនត្រឹមត្រូវនិងការធ្វើផែនការគ្រួសារដោយអាស្រ័យលើចិត្តមនុស្ស ស្ថានភាពសេដ្ឋកិច្ចនិងតម្រូវការសង្គម បានធ្វើឱ្យប៉ះពាល់ដល់ទំនួលខុសត្រូវនិងអត្រារស់នៅ។

ស្ត្រីម្នាក់ដែលរូបនាងមិនមានគម្រោងមានកូននោះ នាងក៏សម្រេចចិត្តធ្វើផែនការគ្រួសារដើម្បីជៀសវាងនូវការមានកូនដោយចៃដន្យ។ ជាមួយគ្នានេះដែរ ការពិចារណារបស់អ្នកចិត្តវិទ្យាមួយរូប បានឱ្យដឹងថា ការសម្រេចចិត្តរបស់នាងគឺជាដំណោះស្រាយដ៏ល្អមួយ។ មនុស្សម្នាក់ៗមានសិទ្ធិសម្រេចចិត្តដើម្បីធ្វើឱ្យគ្រួសារមានសុខុមាលភាព។ ដោយផ្អែកលើហេតុផលនេះ ការរំលូតកូន វាជាបញ្ហាមួយដែលកើតឡើងចំពោះមនុស្សទូទៅនៅពេលដែលពួកគេមិនចង់មានផ្ទៃពោះ។ ជារឿយៗ មានគំរូខ្លះគឺមិនសមស្រប ហើយមិនមានសុវត្ថិភាពទេក្នុងការរំលូតកូន។ ប៉ុន្តែវាមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារមិនឱ្យមានកូនទាក់ទងនឹងការប្រើសម្ភារៈ និងការគោរពតាមវេជ្ជបញ្ជារបស់គ្រូពេទ្យជំនាញ។

នៅមានកត្តាផ្សេងៗទៀតដែលមនុស្សមួយចំនួនមិនបានត្រៀម និងធ្វើការពិចារណានៅពេលពួកគេត្រូវសម្រាលបុត្រ។ ហេតុនេះ ស្ត្រីទាំងនេះគួរធ្វើការសម្រេចចិត្តឱ្យបានច្បាស់លាស់ មិនមែនចេះតែភ្លេចខ្លួនហើយបណ្តោយទៅតាមពេលវេលានោះទេ។ ការមានផ្ទៃពោះ ជាការបំពេញបំណងរបស់មនុស្សទូទៅ ប៉ុន្តែនៅពេលស្ថានភាពណាមួយប្រែប្រួល វាក៏អាចធ្វើឱ្យពួកគេមានការលំបាកផងដែរ។ ឧទាហរណ៍ នៅពេលស្វាមីទទួលមរណភាពឬការមានបញ្ហាវិកាក្នុងគ្រួសារក៏អាចជាផលមិនល្អមួយផងដែរ។ នៅក្នុងកាលៈទេសៈទាំងនេះ វាគឺជាឧបសគ្គដែលកើតឡើងទៅលើជីវិតរបស់ពួកគេនៅពេលពួកគេធ្វើផែនការមិនច្បាស់លាស់។ ផ្ទុយទៅវិញ ការរំលូតកូនអាចជាការព្យាបាលដ៏សមរម្យមួយ ប្រសិនបើយើងស្វែងយល់ដឹងបានច្បាស់ចំពោះស្ថានភាពទាំងនោះ។ ហេតុនេះ វាគឺជាសិទ្ធិដ៏សមហេតុផលមួយក្នុងការសម្រេចចិត្ត នៅពេលដែលពួកគេមិនចង់មានកូន ពីព្រោះមានមនុស្សជាច្រើនគិតថា ពួកគេមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបីបាច់ថែរក្សាកូននៅឡើយ។ ដូចនេះ ចំពោះបញ្ហាទាំងនេះ ប្រសិនបើយើងធ្វើការសម្រេចចិត្តត្រឹម

ត្រូវ នោះយើងមានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើវា។ នៅក្នុងជម្រើសនៃការរម្លូតកូនឱ្យបានសមរម្យ គឺរួមផ្សំផងដែរទៅនឹងតម្រូវការនៃការរស់នៅរបស់មនុស្ស។

ចុងការពិភាក្សាវែកញែក ការធ្វើផែនការគ្រួសារពីបុរាណ មិនមែនជាវិធីសាស្ត្រល្អនោះទេ។ ទោះយ៉ាងណា នៅពេលខ្លះ បញ្ហាជីវភាពគ្រួសារនិងបញ្ហាការស្លាប់របស់ស្វាមី វាក៏អាចឈានទៅរកការផ្លាស់ប្តូរមួយថ្មីទៀតនៅក្នុងការទទួលយកកូន។ មនុស្សមួយចំនួនបានគិតល្អិតល្អន់ចំពោះការសម្រេចចិត្តធ្វើអ្វីមួយ តែមនុស្សខ្លះទៀតពុំសូវគិតវែងឆ្ងាយនោះទេ។ ដូច្នេះចំពោះស្ថានភាពនៃការផ្លាស់ប្តូរគឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងដំណើរការថ្មីមួយយ៉ាងសមស្រប។ ជាទូទៅ យើងមិនចង់ធ្វើអ្វីដែលជាការសម្រេចចិត្តភ្លាមៗ ដែលមិនមានហេតុផលច្បាស់លាស់ដើម្បីធ្វើការលើកលែងនៅក្នុងបញ្ហារម្លូតកូននោះទេ។

## សេចក្តីសន្និដ្ឋាន

បច្ចុប្បន្នពុំមានមូលដ្ឋានទូទៅមួយសម្រាប់ដោះស្រាយនូវគំនិតជំទាស់គ្នាដែលបានលើកឡើងខាងលើនៅឡើយទេ។ ប៉ុន្តែពួកគេត្រូវស្វែងយល់ពីគោលនយោបាយរបស់ប្រទេសខ្លួនថាតើក្នុងកាលៈទេសៈបែបណាឬហេតុផលបែបណាដែលការរម្លូតកូនគួរត្រូវបានអនុញ្ញាត? តើគេពឹងផ្អែកលើសីលធម៌ឬពឹងផ្អែកលើអំណះអំណាងខាងវប្បធម៌(ជំនឿ ប្រពៃណី សាសនា ...)ទាក់ទិននឹងបញ្ហាអំពីការរម្លូតកូននេះ។

យោងតាមមាត្រាទី៨ នៃច្បាប់ស្តីពីការរម្លូតកូននៅប្រទេសកម្ពុជា ការរម្លូតកូនអាចធ្វើទៅបានចំពោះតែគភ៌ណាដែលមានអាយុតិចជាង១២សប្តាហ៍។ លើសពី១២សប្តាហ៍នៃអាយុគភ៌ ការរម្លូតកូនអាចទទួលការនុញ្ញាតបាន លុះត្រាតែក្នុងពេលធ្វើពាគវិនិច្ឆ័យឃើញថា៖

- គភ៌នោះមានភវនីយភាពមិនលូតលាស់ដូចប្រក្រតីឬបង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ
- កូនដែលនឹងកើតមកអាចមានជំងឺធ្ងន់ធ្ងរព្យាបាលពុំជា
- ក្នុងករណីដែលត្រូវបានគេរំលោភបណ្តាលឱ្យមានគភ៌ ការរម្លូតកូនអាចប្រព្រឹត្តទៅបានដោយមិនគិតពីលក្ខខណ្ឌដែលមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមាន។[5]

នៅក្នុងអត្ថបទមានចំណងជើងថា « ការរម្លូតកូននៅខ្មែរស្របច្បាប់ជាង២០ឆ្នាំហើយ តែពលរដ្ឋមួយចំនួននៅមានមន្ទិល » ចុះផ្សាយថ្ងៃចន្ទ ទី ១ ខែតុលា ឆ្នាំ២០១៨ ដែលលើកឡើង

[5] ដកស្រង់អត្ថបទ « ច្បាប់ស្តីពីការរម្លូតកូន ឆ្នាំ១៩៩៧ » ចុះផ្សាយថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨។

ដោយលោកស្រី Amy Williamson នាយិកាអង្គការម៉ារីស្តូបអន្តរជាតិប្រចាំនៅកម្ពុជាមានខ្លឹមសារថា ស្ត្រីកម្ពុជាជាច្រើននាក់មានអារម្មណ៍ភ័យខ្លាចនិងឯកានៅពេលដែលពួកគេដឹងថាខ្លួនមានផ្ទៃពោះដោយឥតព្រាងទុក។ បទពិសោធន៍នៃការឈឺចាប់នេះអាចបង្កជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ។ កង្វះការយល់ដឹងអំពីសិទ្ធិស្របច្បាប់នៃការទទួលសេវារម្លូតកូនអាចនាំឱ្យស្ត្រីយឺតយ៉ាវក្នុងការស្វែងរកសេវាថែទាំសុខភាពនិងអាចឈានទៅដល់សេវារម្លូតកូនដែលគ្មានសុវត្ថិភាព។ អ្នកស្រីបានបន្តថា ពីមួយឆ្នាំទៅមួយឆ្នាំ ស្ត្រីកម្ពុជាជាច្រើន ពិសេសនៅតាមជនបទ មានសុខភាពចុះអន់ខ្សោយដោយសារមានកូនញឹកពេក។ យុវតីមួយចំនួនត្រូវរងគ្រោះដោយសារភាពខ្មាសអៀន រួមជាមួយក្តីភាន់ច្រឡំថា ការរម្លូតកូនគឺជារឿងមិនស្របច្បាប់ រហូតពួកគេធ្វើការសម្រេចចិត្តមិនត្រឹមត្រូវ ហើយងាកទៅធ្វើការរម្លូតកូនដោយខ្លួនឯង និងទៅរកសេវាសម្ងាត់ ឬវិធីរម្លូតបែបបុរាណដែលគ្មានអនាម័យនិងសុវត្ថិភាពទៅវិញ។[6]

## ឯកសារពិគ្រោះ


- « ច្បាប់ស្តីពីការរម្លូតកូន ឆ្នាំ១៩៩៧ » អត្ថបទចុះផ្សាយថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨។
- «ការរំលូតកូននៅខ្មែរស្របច្បាប់ជាង២០ឆ្នាំហើយ តែពលរដ្ឋមួយចំនួននៅមានមន្ទិល » អត្ថបទចុះផ្សាយថ្ងៃចន្ទ ទី១ ខែតុលា ឆ្នាំ២០១៨។
- Ben Bayer, *Science without Philosophy Can't Resolve Abortion Debate,* August *27,2018*
- Mary Vetterling-Bragging, Frederick A. Elliston & Jane English, *Feminism and philosophy,* 1981
- Ned Resnikoff , *Philosophy and the moral issue of abortion,* 01/23/13 04:08PM–UPDATE 09/13/13 08:47AM
- NICHOLAS BUNNIN AND JIYUAN YU , *The Blackwell Dictionary of Western Philosophy,* First published 2004 by Blackwell Publishing Ltd


[6] ដកស្រង់អត្ថបទស្តីពី «ការរំលូតកូននៅខ្មែរស្របច្បាប់ជាង២០ឆ្នាំហើយ តែពលរដ្ឋមួយចំនួននៅមានមន្ទិល » ចុះផ្សាយថ្ងៃចន្ទ ទី១ ខែតុលា ឆ្នាំ២០១៨។